ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ០២៥៩ សនក.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៃក្រសួងសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ /នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញសេចក្តីសម្រេចលេខ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល



អាសយដ្ឋានៈ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទៈ(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែលៈ info@moh.gov.kh
គេហទំព័រៈ www.moh.gov.kh
តេឡេក្រាមៈ t.me/MOHCambodia

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួងសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តមវេជ្ជបណ្ឌិត | **ម៉ី សំអូរ** | រដ្ឋលេខាធិការប្រចាំការក្រសួងសុខាភិបាល | ប្រធាន |
| ២- ឯកឧត្តមវេជ្ជបណ្ឌិត | **ជូ ម៉េងចាន់** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- ឯកឧត្តមវេជ្ជបណ្ឌិត | **ស៊ឹម ស៊ូយេង** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤- លោក | **ម៉ៅ សុខលីម** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោកវេជ្ជបណ្ឌិត | **ហួយ សេរីវឌ្ឍនៈ** | អគ្គនាយករងបច្ចេកទេសសុខាភិបាល | សមាជិក |
| ៦- លោក | **ហ៊ុយ ឆេងតារារ័ត្ន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម | **ហុក ខៀវ** | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៨- ឯកឧត្តមវេជ្ជបណ្ឌិត | **សុខ ស្រ៊ុន** | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ៩- លោកស្រីសាស្ត្រ.ជំនួយ | **ទូច សុខនាង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១០- លោកវេជ្ជបណ្ឌិត | **អ៊ុំ សំសុង** | ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ១១- លោកឱសថការី | **លុក សាគី** | ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង | សមាជិក |
| ១២- លោក | **សុខ សំណាង** | ប្រធាននាយកដ្ឋានសុខាភិបាលឱជីថល | សមាជិក |
| ១៣- លោក | **គឹម សាឡួន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ១៤- លោកវេជ្ជបណ្ឌិត | **ឆាយ គ្រី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ ធនធានមនុស្ស | សមាជិក |
| ១៥- លោកឱសថការី | **សៀ ថុល** | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង | សមាជិក។ |

**ប្រការ២.-**

ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួងសុខាភិបាល មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពអនុវត្តការត្រួតពិនិត្យនិងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសុខាភិបាល
- សិក្សានិងរៀបចំវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- រៀបចំរបាយការណ៍ស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាលពិនិត្យនិងសម្រេច
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាល
- ផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**ប្រការ៣.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួងសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោកទន្តបណ្ឌិត | **គាំ ស៊ីទួន** | អនុប្រធាននាយកដ្ឋាននីតិកម្ម | ប្រធាន |
| ២- លោកវេជ្ជបណ្ឌិត | **ទិត សួស្តី** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | អនុប្រធាន |
| ៣- លោកទន្តបណ្ឌិត | **ពឹង ពិសិដ្ឋ** | ប្រធានការិយាល័យវិវាទសុខាភិបាល និងស្រាវជ្រាវនៃនាយកដ្ឋាននីតិកម្ម | សមាជិក |
| ៤- លោកវេជ្ជបណ្ឌិត | **គ្រុយ គៀង** | ប្រធានការិយាល័យចាត់តាំង នៃនាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ៥- លោកឱសថការី | **ហៀង គឹមសៀត** | ប្រធានការិយាល័យនិយ័តកម្មឱសថ នៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង | សមាជិក |
| ៦- លោកវេជ្ជបណ្ឌិត | **សោម សីហារ័ត្ន** | ប្រធានការិយាល័យនិយ័តកម្ម និងក្រមសីលធម៌នៃនាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ៧- លោកស្រី | **ឡុង សេរីរស្មី** | មន្ត្រីវិទ្យាស្ថានជាតិសុខភាពសាធារណៈ | សមាជិក |
| ៨- លោក | **អេង តារុន** | មន្ត្រីនាយកដ្ឋាននីតិកម្ម | សមាជិក។ |

**ប្រការ៤.-**

លេខាធិការដ្ឋានក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួងសុខាភិបាលមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលរៀបចំរាល់កិច្ចការរបស់ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- រៀបចំផែនការសម្រាប់ដំណើរការរបស់ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- រៀបចំរបាយការណ៍អំពីលទ្ធផលការងារជូនក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីប្រធានក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួងសុខាភិបាល។

**ប្រការ៥.-**

ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងលេខាធិការដ្ឋាន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ករណីប្រធានអវត្តមាន ឬករណីចាំបាច់ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៦.-**

ប្រកាសលេខ០២២ ស.នក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តនៃក្រសួងសុខាភិបាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១ រោច ខែ ភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ